# គណៈកម្មាធិការ ខុមហ្វ្រែល ~ គណៈកម្មាធិការ និកហ្វិច ~ ក្រុមប្រឹក្សាយុវជនកម្ពុជា

## របាយការណ៍វាយតម្លៃរួមចុងក្រោយ ស្តីពី
## ការរកឃើញ និងការសន្និដ្ឋាន
## នៅ ថ្ងៃស ថ្ងៃបោះឆ្នោត រាប់សន្លឹកឆ្នោត និងក្រោយថ្ងៃបោះឆ្នោត
## នៃដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់អាណត្តិទី ២ ឆ្នាំ ២០០៧

ភ្នំពេញ ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០៧

គណៈកម្មាធិការខុមហ្វ្រែល គណៈកម្មាធិការនិកហ្វិច ក្រុមប្រឹក្សាយុវជនកម្ពុជា បានសហការដាក់ពង្រាយអ្នកសង្កេត-ការណ៍ប្រហែល ១៨ ០០០ នាក់ រួមទាំងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ប្រមាណជាង ២០ ស្ថាប័នផ្សេងទៀតសរុបប្រមាណជាង ១ ០០០ នាក់ និងរួមទាំងវេទិកានៃប្រជាពលរដ្ឋស្តីពីកម្ពុជា-ប្រទេសជប៉ុន PEFOC,J ។

ជាទូទៅ សម្ព័ន្ធអង្គការសង្គមស៊ីវិលដែលបានចូលរួមសង្កេតការបោះឆ្នោត រកឃើញ និងសន្និដ្ឋានថា ដំណើរការបោះ-ឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់អាណត្តិទី ២ នាថ្ងៃទី ១ មេសា ២០០៧ នេះ បានប្រព្រឹត្តទៅក្នុងលក្ខណៈល្អ **លើការចាត់ចែងនីតិវិធីដំណើរការបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅក្នុងការិយាល័យជាងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា**ឃុំ/សង្កាត់អាណត្តិទី ១ ឆ្នាំ ២០០២ ។ ម្យ៉ាង ការផ្ទៀងផ្ទាត់លទ្ធផលបោះឆ្នោតផ្លូវការបឋមរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ជាមួយលទ្ធផលប្រមូលផ្ទាល់ពីការិយាល័យរាប់សន្លឹកឆ្នោតរបស់អ្នកសង្កេតការណ៍ ខុមហ្វ្រែល និងនិកហ្វិច នៅឃុំ/សង្កាត់មួយចំនួន បានបង្ហាញថា **មិនមានការខុសគ្នាច្រើនដែលមានកំរិតរហូតដល់ប៉ះពាល់ចំនួនអាសនៈរបស់គណបក្សនយោបាយនោះទេ**។

ចំនួននៃភាពមិនប្រក្រតីនៅក្នុងការិយាល័យបោះឆ្នោត/រាប់សន្លឹកឆ្នោត **បានធ្លាក់ចុះពី ១.១១៣ ករណី នៅឆ្នាំ ២០០២ មក ៨២២ ករណីនៅឆ្នាំ២០០៧** (ក្នុងការិយាល័យចំនួន ៦០៩ ដែលយើងបានទទួលរបាយការណ៍) ប៉ុន្តែ**មានភាពមិនប្រក្រតីនៅខាងក្រៅការិយាល័យបោះឆ្នោត/រាប់សន្លឹកឆ្នោតជាច្រើន** ដែលពុំទាន់បានកែលម្អ រួមទាំង**វត្តមានអាជ្ញាធរនៅជុំវិញការិយាល័យបោះឆ្នោត** ជាមួយនឹងសកម្មភាពដែលមិនស្របតាមច្បាប់ និងនីតិវិធីនានាពាក់ព័ន្ធនឹងការបោះឆ្នោត ។

មានប្រជាពលរដ្ឋប្រមាណតែ ៦៦% (ប្រហែលជាង ៥ លាន ១ សែន នាក់) នៃអ្នកដែលមានឈ្មោះបោះឆ្នោតទូទាំងប្រទេសប្រមាណ ៧ លាន ៨ សែននាក់ប៉ុណ្ណោះបានទៅបោះឆ្នោតដើម្បីជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់របស់ខ្លួន ។ ដូច្នេះ **អ្នកមានសិទ្ធិបោះឆ្នោតប្រមាណជាង ២ លាន ៥ សែននាក់ មិនបានទៅបោះឆ្នោត**។ ក្នុងចំណោមនោះ មានអ្នកបោះឆ្នោត បានចេញទៅបោះឆ្នោត ប៉ុន្តែបានជួបឧបសគ្គ ដែលមិនអាចឱ្យបោះឆ្នោតបានប្រហែល ១៨,៥០% ។

យើងក៏មានការរកឃើញផងដែរថា អាជ្ញាធររៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់មិនបានគោរព និងអនុវត្តតាមនីតិ-វិធីក្នុងការទទួល និងដោះស្រាយពាក្យបណ្ដឹងត្រឹមត្រូវពេញលេញនោះទេ។ យើងមានការព្រួយបារម្ភអំពីការបំភិតបំភ័យដល់សកម្មជន និងប្រជាពលរដ្ឋដែលមិនគាំទ្រគណបក្សកាន់អំណាច ក្រោយពេលដឹងលទ្ធផលបណ្ដោះអាសន្ន។

**<u>មូលហេតុមួយចំនួននៃអ្នកមិនបានបោះឆ្នោត</u>**

ទាក់ទិនទៅនឹងអ្នកមិនចេញទៅបោះឆ្នោត ក្រោយពេលបោះឆ្នោតភ្លាម ខុមហ្វ្រែល បានចុះធ្វើការស្រាវជ្រាវចំពោះអ្នកបោះឆ្នោតចំនួន ២៩០ នាក់ ក្នុង ១៥ ឃុំ/សង្កាត់ នៃ ១៥ ខេត្ត/ក្រុង ទៅលើអ្នកមិនបានបោះឆ្នោត (ដោយពិនិត្យទៅលើម្រាមដៃ ពុំមានទឹកខ្មៅលុបមិនជ្រះ) អំពីមូលហេតុមិនបានបោះឆ្នោត។ លទ្ធផលបានបង្ហាញថា:

- មានអ្នកបោះឆ្នោតចំនួន ២៣៦ នាក់ ប្រហែល ៨១,៥០% នៃអ្នកមិនបានបោះឆ្នោតចំនួន ២៩០ នាក់ ក្នុងនោះដោយសារមូលហេតុ:
  - ២៨% ពុំមានសិទ្ធិបោះឆ្នោតដោយសារមិនបានទៅចុះឈ្មោះបោះឆ្នោត (ស្មើនឹង ៦៦ នាក់ ក្នុងចំណោម ២៣៦ នាក់)
  - ៩% **មិនបានទទួលប័ណ្ណព័ត៌មានអ្នកបោះឆ្នោត** (ស្មើនឹង ២២ នាក់នៃ ២៣៦ នាក់) ដែលអ្នកទាំងនោះ **សង្ស័យថា ខ្លួនពុំមានសិទ្ធិបោះឆ្នោត**។
  - ៦៣% ធ្វើចំណាកស្រុក រថយន្តឈ្នួលឡើងថ្លៃ ក្បៀកចូលឆ្នាំខ្មែរ និងមិនមានឆន្ទៈទៅបោះឆ្នោត (ស្មើនឹង ១៤៨ នាក់នៃ ២៣៦ នាក់)។
- ចំពោះអ្នកបានចេញទៅបោះឆ្នោតហើយជួបឧបសគ្គ (ដោយរកឈ្មោះ រកការិយាល័យបោះឆ្នោតមិនឃើញជាដើម) ខុមហ្វ្រែល បានរកឃើញថា **មានអ្នកបោះឆ្នោតចំនួន ៥៤ នាក់ ក្នុងចំណោម ២៩០ នាក់** ប្រហែល **១៨,៥០% បានព្យាយាមទៅបោះឆ្នោត ប៉ុន្តែ ត្រូវបានខកខានមិនបានបោះឆ្នោត** ក្នុងនោះដោយសារមូលហេតុ
  - **មានតែប័ណ្ណព័ត៌មានអ្នកបោះឆ្នោតមួយមុខគត់ (ពុំមានឯកសារបញ្ជាក់អត្តសញ្ញាណផ្សេងទៀតដែលអាចប្រើប្រាស់នៅថ្ងៃបោះឆ្នោតបាន)**
  - **រកឈ្មោះមិនឃើញក្នុងបញ្ជីឈ្មោះ**
  - **រកការិយាល័យបោះឆ្នោតមិនឃើញ**
  - **បើទោះអ្នកបោះឆ្នោតខ្លះមានប័ណ្ណព័ត៌មានអ្នកបោះឆ្នោតក៏ដោយ ក៏មានការខុសទិន្នន័យ/ព័ត៌មានរវាងឯកសារ បញ្ជាក់អត្តសញ្ញាណ និងបញ្ជីឈ្មោះបោះឆ្នោត**

**<u>ភាពមិនប្រក្រតីនៅថ្ងៃ ស និងអំឡុងថ្ងៃបោះឆ្នោត</u>**

ភាពមិនប្រក្រតី ដែលរួមមានប្រមាណ ៧២៤ ករណីដែលកើតមានក្នុងការិយាល័យចំនួន ៥២២ នៅស្ទើរគ្រប់ខេត្ត/ក្រុង ដូចជាខេត្តកំពង់ចាម ២០៤ ករណី, សៀមរាប ៨៩ ករណី, ភ្នំពេញ ៧៥ ករណី, កំពង់ស្ពឺ ៤៤ ករណី, ព្រះវិហារ ៣៨ ករណី, កោះកុង ៣៧ ករណី, កំពង់ឆ្នាំង ២៧ ករណី, ស្វាយរៀង ២៤ ករណី, កំពង់ធំ ២១ ករណី, ពោធិ៍សាត់ ១៧ ករណី ជាដើម ដែលត្រូវបានអ្នកសង្កេតការណ៍ រាយការណ៍មក ក្នុងនោះរួមមាន:

- សកម្មភាពឃោសនាបោះឆ្នោតរំលោភនីតិវិធី ជាពិសេសនៅថ្ងៃស ចំនួន៣៨ ករណី ដូចជា សកម្មភាពឃោសនា និងការចែកអំណោយរបស់គណបក្សប្រជាជនកម្ពុជា នៅរាជធានីភ្នំពេញ ខេត្តតាកែវ កំពង់ឆ្នាំង កំពង់ចាម បាត់ដំបង បន្ទាយមានជ័យ និងករណីគណបក្សសមរង្ស៊ី បានបិទផ្ទាំងក្រណាត់ឃោសនា បិទរូបភាព នៅខេត្តកំពង់ស្ពឺ (ឃុំពោធិអង្រ្គង ស្រុកបរសេដ្ឋ) ជាដើម។
- ការបញ្ជូនសម្ភារៈបោះឆ្នោតមានការយឺតយ៉ាវ និងការខ្វះសម្ភារៈបោះឆ្នោត ដែលធ្វើឱ្យមានការរាំងស្ទះដល់ការបើកការិយាល័យបោះឆ្នោត ចំនួន ៨ ករណី។
- បរិយាកាសនយោបាយ ដែលគ្មានសុវត្ថិភាពនៅក្នុងភូមិជុំវិញការិយាល័យបោះឆ្នោត ចំនួន ១៣ ករណី ដូចជា នៅខេត្តបាត់ដំបង ខេត្តកំពង់ឆ្នាំង ជាដើម។
- មានសកម្មភាពដឹកជញ្ជូន ឬផ្តល់ជាលុយកាក់ ដល់អ្នកបោះឆ្នោតក្នុងទ្រង់ទ្រាយធំទៅបោះឆ្នោត ពីសំណាក់សកម្មជនគណបក្សនយោបាយមួយចំនួន ជាពិសេសគណបក្សកាន់អំណាច ចំនួន ២៥ ករណី។ ករណីនេះកើតឡើងនៅក្នុងក្រុងភ្នំពេញ ខេត្តឧត្តរមានជ័យ រតនគិរី ពោធិ៍សាត់ ព្រៃវែង កោះកុង កណ្តាល កំពង់ឆ្នាំង កំពង់ចាម បន្ទាយមានជ័យ បាត់ដំបង និងតាកែវ ជាដើម។ ជាពិសេសនៅខេត្តតាកែវ មេភូមិ ប្រធានក្រុមមួយចំនួនរបស់គណបក្សប្រជាជនកម្ពុជា បានសន្យាជាមួយអ្នកគាំទ្រគណបក្សសមរង្ស៊ីមួយចំនួនថានឹងឱ្យសារុង និងប្រាក់ដប់ម៉ឺនរៀលដោយមិនបាច់ទៅបោះឆ្នោត។
- វត្តមានដោយខុសច្បាប់របស់អាជ្ញាធរមូលដ្ឋាន ជាពិសេសមេភូមិចិតនៅជុំវិញការិយាល័យបោះឆ្នោតដើម្បីតាមឃ្លាំមើលអ្នកបោះឆ្នោត ដើម្បីណែនាំអ្នកបោះឆ្នោតឱ្យគូសឱ្យគណបក្សរបស់ខ្លួន ដែលជាហេតុបណ្តាលឱ្យអ្នកបោះឆ្នោតមួយចំនួនមានអារម្មណ៍ភ័យខ្លាច ចំនួន ១០៤ ករណី។ ករណីនេះកើតឡើងនៅតាមការិយាល័យបោះឆ្នោតមួយចំនួនក្នុងខេត្តឧត្តរមានជ័យ តាកែវ សៀមរាប ព្រះវិហារ ក្រចេះ កោះកុង កណ្តាល កំពង់ធំ កំពង់ស្ពឺ កំពង់ឆ្នាំង កំពង់ចាម បន្ទាយមានជ័យ និងខេត្តបាត់ដំបង។
- មានការអនុញ្ញាតឱ្យកងកម្លាំងប្រដាប់អាវុធក្នុងឯកសណ្ឋាន និងការយកអាវុធជាតិផ្ទុះ ចូលទៅក្នុងការិយាល័យបោះឆ្នោត មាន ៣៥ ករណី ក្នុងខេត្តឧត្តរមានជ័យ ក្រុងព្រះសីហនុ ព្រះវិហារ ក្រុងភ្នំពេញ ក្រចេះ កំពង់ឆ្នាំង កំពង់ចាម បាត់ដំបង និងបន្ទាយមានជ័យ។ ឧទាហរណ៍ដូចជានៅការិយាល័យមួយក្នុងឃុំទ្រៀល ស្រុកបារាយណ៍ ខេត្តកំពង់ធំ ជាដើម ដែលមាននគរបាល រហូតដល់ជាង ៩០ នាក់ បានចូលទៅបោះឆ្នោត។
- មានការបង្កឱ្យមានការភ័យខ្លាច អសន្តិសុខ ការគំរាមកំហែង នៅខាងក្នុង ឬខាងក្រៅការិយាល័យបោះឆ្នោត ដោយគ្មានការដោះស្រាយពីមន្ត្រីមានសមត្ថកិច្ច ចំនួន ២០ ករណី ដូចជានៅតាមការិយាល័យមួយចំនួននៅក្នុងខេត្តឧត្តរមានជ័យ បាត់ដំបង បន្ទាយមានជ័យ។
- នីតិវិធីនៃការបោះឆ្នោត មិនត្រូវបានគោរពពេញលេញដោយមន្ត្រីការិយាល័យ ដែលនាំមកនូវភាពមិនប្រក្រតី ចំនួន ៣១៣ ករណីនៅក្នុងការិយាល័យបោះឆ្នោត។ ករណីភាគច្រើនកើតមានឡើងនៅទីក្រុងភ្នំពេញ កំពង់ចាម

ព្រះវិហារ សៀមរាប តាកែវ កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ បាត់ដំបង ពោធិ៍សាត់ ស្វាយរៀង ឧត្តរមានជ័យ និងកោះកុង។ ក្នុងនោះ រួមមាន:

- ការមកដល់យឺត នៃមន្ត្រីការិយាល័យបោះឆ្នោត ឬសម្ភារៈបោះឆ្នោតចំនួន ២៤ ករណី។
- ភាពយឺតយ៉ាវនៃការបើកការិយាល័យបោះឆ្នោត ចំនួន ២៥ ករណី។
- ការមិនបង្ហាញហិបឆ្នោតទទេ ការមិនសរសេរលេខកូដ ការមិនវាយត្រានៅលើហិបឆ្នោត ការរៀបចំការិយាល័យមិនតាមការណែនាំរបស់ គ.ជ.ប មានចំនួន ៤០ ករណី។
- ការធានាមិនបានទូវភាពសម្ងាត់នៃសន្លឹកឆ្នោតចំនួន ១៨៥ ករណី (ការិយាល័យមួយចំនួននៅផ្នែកខាងក្នុងនៃបន្ទប់សម្ងាត់អាចមើលឃើញពីខាងក្រៅ និងមានការអនុញ្ញាតឱ្យអ្នកបោះឆ្នោតម្តងលើសពីម្នាក់ចូលបន្ទប់សម្ងាត់គូសសន្លឹកឆ្នោត និងមានការសួរនាំគ្នារកកន្លែងគូសលើសន្លឹកឆ្នោត)។
- ការមិនពិនិត្យម្រាមដៃរបស់អ្នកបោះឆ្នោតរកមើលទឹកខ្មៅ មុនពេលប្រគល់សន្លឹកឆ្នោតឱ្យ ឬការមិនជ្រលក់ម្រាមដៃអ្នកបោះឆ្នោតនឹងទឹកថ្នាំមិនអាចលុបជ្រះបាន ឬការមិនបានផ្ទៀងផ្ទាត់ឯកសារបញ្ជាក់អត្តសញ្ញាណជាមួយនឹងបញ្ជី ចំនួន ៣៣ ករណី។
- ការផ្អាក ឬបិទការិយាល័យបោះឆ្នោតដោយថាហេតុ ចំនួន ៦ ករណី។
- ការបដិសេធរបស់មន្ត្រីការិយាល័យក្នុងការផ្តល់ទំរង់ពាក្យបណ្តឹងទៅឱ្យអ្នកបោះឆ្នោត ឬភ្នាក់ងារគណបក្សនយោបាយ ចំនួន ១៣ ករណី។
- អ្នកគ្មានសិទ្ធិបោះឆ្នោត ឬអ្នកមានស្នាមទឹកខ្មៅនៅម្រាមដៃ ត្រូវបានអនុញ្ញាតឱ្យបោះឆ្នោតម្តងទៀត ចំនួន ៦ ករណី។
- មានករណីសន្លឹកឆ្នោតត្រូវបានគេព្យាយាមយកចេញមកខាងក្រៅការិយាល័យបោះឆ្នោតដើម្បីឱ្យអ្នកបោះ-ឆ្នោតផ្សេងគូស ចំនួន ២ ករណី។ ករណីមួយកើតឡើងនៅការិយាល័យលេខ ០៣៣២ ក្នុងឃុំសំរោងយារ ស្រុកពួក ខេត្តសៀមរាប ដោយមានមន្ត្រីការិយាល័យបោះឆ្នោតអនុញ្ញាតឱ្យអ្នកបោះឆ្នោតម្នាក់យកសន្លឹកឆ្នោតទៅឱ្យស្ត្រីទើបសំរាលកូននៅក្នុងមន្ទីរពេទ្យគូស។

និងមានករណីជាច្រើនផ្សេងទៀតដូចជា

- មានការអនុញ្ញាតឱ្យអ្នកបោះឆ្នោតច្រើនរាប់រយនាក់ ពាក់អាវមានរូបសញ្ញាគណបក្សនយោបាយនានា ជាពិសេស គឺអាវគណបក្សប្រជាជនកម្ពុជាចូលបោះឆ្នោត។
- មន្ត្រីការិយាល័យខ្លះទាមទាររកលេខកូដការិយាល័យនៅលើប័ណ្ណអ្នកសង្កេតការណ៍ ទើបឱ្យចូលសង្កេតការ ឬ រារាំងបង្កឧបសគ្គ ឬ ហាមមិនឱ្យសង្កេតការណ៍តែម្តង ដូចជានៅតាមការិយាល័យមួយចំនួនក្នុងខេត្តបាត់ដំបង កំពង់ស្ពឺ តាកែវ ព្រៃវែង សៀមរាប ឧត្តរមានជ័យ ក្រុងភ្នំពេញ កណ្តាល ជាដើម។
- មានតែប័ណ្ណព័ត៌មានអាចបោះឆ្នោតបាន នៅការិយាល័យមួយចំនួន។

○ ឬក្បៀបសង្កត់ឱ្យអ្នកសង្កេតការណ៍ នៃអង្គការមិនមែនរដ្ឋាភិបាល និងភ្នាក់ងារគណបក្សនយោបាយអង្គុយតែមួយកន្លែង ដោយពុំឱ្យចល័តក្នុងការិយាល័យ ។

○ ការបង្ខំឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ចុះហត្ថលេខាលើទំរង់ស្តីពីកំណត់ហេតុលទ្ធផលបោះឆ្នោត មុនការបិទបញ្ចប់ការបោះឆ្នោត ។

*__ភាពមិនប្រក្រតីក្នុងដំណើរការរាប់សន្លឹកឆ្នោត__*

នៅពេលរាប់សន្លឹកឆ្នោត ការសង្កេតឃើញថា មន្ត្រីការិយាល័យភាគច្រើន មិនទាន់យល់អំពីការកំណត់សុពលភាព ឬអសុពលភាព (បានការ ឬមិនបានការ) នៃសន្លឹកឆ្នោត មានភាពមិនប្រក្រតីចំនួន ៩៨ ករណី កើតមានឡើងនៅក្នុងការិយាល័យចំនួន ៨៧ នៅស្ទើរគ្រប់ខេត្ត/ក្រុងដូចជា ភ្នំពេញ ៣៧ ករណី, កំពង់ចាម ៣៣ ករណី, កំពង់ធំ ៦ ករណី, តាកែវ ៥ ករណី, កែប ៥ ករណី ។ មានភាពមិនប្រក្រតីផ្សេងទៀត ដូចខាងក្រោមនេះ :

- ការជ្រុះសន្លឹកឆ្នោតរប៉ាត់រប៉ាយនៅពេលរាប់សន្លឹកឆ្នោត ចំនួន ១១ ករណី ។
- ការមិនបង្ហាញសន្លឹកឆ្នោតទៅអ្នកសង្កេតការណ៍ ឬភ្នាក់ងារគណបក្សនយោបាយ ចំនួន ១៨ ករណី ។

ភាពមិនប្រក្រតីនៃការហៅលទ្ធផលនៅលើសន្លឹកឆ្នោត ដូចជាការបន្លំសន្លឹកឆ្នោតចំនួន ៩ ករណី (ការហៅខុសញ្ញឹកញាប់លទ្ធផលនៅក្នុងសន្លឹកឆ្នោត និងការគូសខុសញ្ញឹកញាប់នៅលើក្តារខៀនពីលទ្ធផល ។

- អតុល្យភាពនៃសន្លឹកឆ្នោត (ដុំសន្លឹកឆ្នោតខ្លះមានលើស ១ ឬ ២ ខ្វះ ១ ឬ ២ សន្លឹកក្នុង ១ ដុំ ។ ក្នុងមួយដុំមាន ៥0 សន្លឹកតែប៉ុណ្ណោះ) ដូចជាករណីនៅខេត្តកំពង់ឆ្នាំង ការិយាល័យលេខ 000១ ឃុំអញ្ចាញរូង ស្រុកបរិបូណ៌ មានសន្លឹកឆ្នោត លើសចំនួន ២ សន្លឹក គ្មានលេខកូដនៅក្នុងក្បាលទី ៩ មួយសន្លឹក និងក្បាលទី ១៣ មួយសន្លឹក ។
- ការបំភិតបំភ័យ ការគំរាមកំហែង និងការរំខានដំណើរការរាប់សន្លឹកឆ្នោតមាន ២0 ករណី ។

នៅក្នុងថ្ងៃបោះឆ្នោតនោះផងដែរ ការសង្កេតឃើញមាន ករណីឆេះផ្ទះសកម្មជនរបស់គណបក្សសមរង្ស៊ីមួយខ្នង នៅឃុំរកាពប្រាំ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម កាលពី វេលាម៉ោង ១០ យប់ ថ្ងៃទី 0១ មេសា ២00៧ ដោយពុំមានមូលហេតុច្បាស់លាស់ ។

*__បណ្តឹងថ្ងៃបោះឆ្នោត រាប់សន្លឹកឆ្នោត__*

មានបណ្តឹងមួយចំនួន (រួមទាំងបណ្តឹងផ្ទាល់មាត់ និងបំពេញទំរង់ ១២0២) ដែលធ្វើឡើងដោយគណបក្សនយោបាយចំពោះដំណើរការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។ មានសេចក្តីរាយការណ៍ថា មន្ត្រីការិយាល័យបោះឆ្នោតមិនចង់ផ្តល់ទំរង់បណ្តឹង និងម្យ៉ាងទៀតភ្នាក់ងារគណបក្ស មានការភ័យខ្លាចនៅពេលមានការប្តឹងផ្តល់ ។ ការសង្កេតរកឃើញថា ដំណើរការ**ដោះស្រាយបណ្តឹងរបស់អាជ្ញាធររៀបចំការបោះឆ្នោតនៅគ្រប់លំដាប់ថ្នាក់ ភាគច្រើន (រហូតដល់ ៨៤% នៃចំនួនបណ្តឹងសរុបចំនួន ១១៩ ករណី) គឺត្រូវបានបដិសេធ ដោយលើកហេតុផលថា ខ្វះឯកសារ ភស្តុតាង ឬគ្មានមូលដ្ឋានច្បាប់ច្បាស់លាស់ ឬបណ្តឹងមិនគ្រប់លក្ខណៈសម្បត្តិ ដោយពុំមានការចុះស៊ើបអង្កេតឱ្យបានស៊ីជំរៅ រកនូវអ្វីដែលជាការខ្វះខាតនោះទេ**

ដោយមន្ត្រីទទួលបន្ទុកលើកហេតុផលថា **ពេលវេលាមិនអំណោយផល (ដោយមានអាជ្ញាយុកាលកំណត់)**។ មានបណ្តឹងភាគតិចប៉ុណ្ណោះ ដែលត្រូវបានលើកយកមកដោះស្រាយដោយ**វិធីសំរុះសំរួល**។

ជាក់ស្តែង មានបណ្តឹងចំនួន ២៣ ដែលបានដាក់ទៅគណៈកម្មាការឃុំ/សង្កាត់រៀបចំការបោះឆ្នោត (គឃ/សប) ពីសំណាក់គណបក្សនយោបាយ អំពីបញ្ហាពេលបោះឆ្នោត រាប់សន្លឹកឆ្នោត។ ក្នុងនោះ មានបណ្តឹងចំនួន ១៣ ស្មើ នឹង ៥៦% ត្រូវបានបដិសេធ ដោយយោងលើមូលហេតុ**បណ្តឹងគ្មានមូលដ្ឋានច្បាប់ច្បាស់លាស់**។ មានតែបណ្តឹងចំនួន ៨ ប៉ុណ្ណោះ ត្រូវបានដោះស្រាយដោយវិធីសំរុះសំរួល ហើយមានបណ្តឹងចំនួន ១ ត្រូវបានភាគីដើមបណ្តឹងមិនយល់ព្រម និងមានការ យល់ព្រមតាមបណ្តឹងរបស់ភាគីដើមចោទចំនួន ១ បណ្តឹង។

ចំណែកឯនៅថ្នាក់ខេត្ត/ក្រុងរៀបចំការបោះឆ្នោត (គខ/កប) មានបណ្តឹងចំនួន ៦១ ត្រូវបានដើមបណ្តឹងដាក់មក។ ក្នុងនោះមានបណ្តឹងចំនួន ៥៤ ស្មើនឹង ៨៨% ត្រូវបានបដិសេធ ដោយយោងលើមូលហេតុ**បណ្តឹងមិនគ្រប់លក្ខណៈសម្បត្តិ**។ មានបណ្តឹងចំនួនតែ ៣ ប៉ុណ្ណោះត្រូវបានដោះស្រាយដោយយល់ស្របតាមភាគីដើមបណ្តឹង។

រីឯនៅថ្នាក់ គជប វិញ មានបណ្តឹងចំនួន ៣៥ ត្រូវបានគេរាយការណ៍។ ក្នុងនោះបណ្តឹងចំនួន ៣៤ ស្មើនឹង ៩៧% ត្រូវបាន គជប បដិសេធ ដោយលើកមូលហេតុប្រហាក់ប្រហែលនឹង គឃ/សប និងគខ/កប ដែរ ព្រមទាំងបញ្ជាក់ថា ហួសអាជ្ញាយុកាល ខ្វះសាក្សីជាដើម។

**<u>ករណីឃុំប៉ោយប៉ែត</u>**

ការសង្កេតឃើញថា **មានភាពមិនប្រក្រតី ជាពិសេសដែលអាចធ្វើឱ្យប៉ះពាល់លើដំណើរការ និងលទ្ធផលបោះឆ្នោតនៅឃុំប៉ោយប៉ែត** ខេត្តបន្ទាយមានជ័យ។ **មានអ្នកមិនបានបោះឆ្នោតប្រហែល ៧០%** ក្នុងចំណោមអ្នកបោះឆ្នោតចំនួន ៦៣.៩៧៧ នាក់ ដែលមានសិទ្ធិអ្នកបោះឆ្នោតខ្លះ បានជួបឧបសគ្គក្នុងការទៅបោះឆ្នោត។ មានពាក្យបណ្តឹងមួយចំនួនពីគណបក្សសមរង្ស៊ី (រួមទាំងបណ្តឹងផ្ទាល់មាត់) ក្នុងនោះ មានបណ្តឹងសំខាន់មួយចំនួន ត្រូវបានបដិសេធដោយ គខប និង គជប។ បណ្តឹងរបស់គណបក្សសមរង្ស៊ី ដែលលើកឡើងអំពីចំនួន**អ្នកបោះឆ្នោតទាប** ជាមូលហេតុនៃការស្នើសុំឱ្យបោះឆ្នោតឡើងវិញនោះ ក៏ត្រូវបានបដិសេធដែរ។ ការសង្កេត និងអង្កេតបន្ថែមរកឃើញថា មានអ្នកមានសិទ្ធិបោះឆ្នោតមួយចំនួនណាដែលមិនបានបោះឆ្នោតនោះ បានជួបឧបសគ្គដូចជា **មិនអាចរកឈ្មោះនៅលើបញ្ជី និងការិយាល័យបោះឆ្នោតឃើញ**។ **មានបញ្ហានៃកម្មករខ្មែរធ្វើការនៅប្រទេសថៃ ហើយបានជួបការលំបាកក្នុងការត្រឡប់មកបោះឆ្នោតវិញ** ព្រមទាំងការមិន**បង្កឱកាសឱ្យកម្មករកាស៊ីណូចេញទៅបោះឆ្នោត**។ អ្នកមានសិទ្ធិបោះឆ្នោតមួយចំនួនទៀត ជួបបញ្ហាដែលមិនមានឯកសារបញ្ជាក់អត្តសញ្ញាណ រួមផ្សំជាមួយ**ការមិនបានទទួលប័ណ្ណព័ត៌មានអ្នកបោះឆ្នោត**។

ចំពោះករណីនេះ អ្នកសង្កេតការណ៍ ខុមហ្វ្រែល បានរកឃើញភាពមិនប្រក្រតីជាក់ស្តែងយ៉ាងតិចចំនួន ១៦ ករណីក្នុងការិយាល័យមួយចំនួន នៅក្នុងឃុំនេះ។ ករណីទាំងនោះមានដូចជា មានការអនុញ្ញាតឱ្យកងកំលាំងប្រដាប់អាវុធស្លៀកពាក់ឯកសណ្ឋានចូលក្នុងការិយាល័យបោះឆ្នោត ការមានឈ្មោះដូចគ្នាអ្នកមកក្រោយ មិនត្រូវអនុញ្ញាតឱ្យបោះឆ្នោត មាន

មន្ត្រីគណបក្សប្រជាជនកម្ពុជាឆែកបញ្ជីឈ្មោះអ្នកបោះឆ្នោត មន្ត្រីគណបក្សប្រជាជនកម្ពុជាបានដើរចល័តតាមការិយាល័យចំនួន ២២ នៅទីនោះ ដោយបើកសម្លេងវិទ្យុទាក់ទងដោយមានឮសំលេងខ្លាំងៗថា បោះឆ្នោតឱ្យគណបក្សប្រជាជនកម្ពុជា តំណាងគណបក្សនរោត្តមរណឫទ្ធិ បានឃ្លាំមើលអ្នកបោះឆោតនៅមុខការិយាល័យបោះឆ្នោតមួយចំនួន តំណាងគណបក្សរណសិរ្សសង្គមជាតិនិយម ក៏បានតាមឃ្លាំមើលតាមការិយាល័យមួយចំនួនផងដែរ។

<u>បរិយាកាសបំភិតបំភ័យក្រោយពេលបោះឆ្នោត</u>

ខុមហ្វ្រែល បានសង្កេតឃើញថា នៅក្រោយការបោះឆ្នោតមានការបំភិតបំភ័យទៅលើសកម្មជនគណបក្សនយោបាយ និងប្រជាពលរដ្ឋនៅតំបន់មួយចំនួន។ ការប្រើអំពើហឹង្សា ការគំរាមកំហែង ជាពិសេសគឺកើតចេញពីការរើសអើងខាងនយោបាយ (ការជេរ្យមដាម តិះដៀលតាមរយៈពាក្យសម្តី ចំពោះសកម្មជនគណបក្សមិនកាន់អំណាច) ពីសំណាក់អាជ្ញាធរមូលដ្ឋាន មេភូមិ មេឃុំ ការគំរាមកំហែង និងករណីឃាតកម្មទៅលើបេក្ខជន និងសកម្មជនគណបក្សជំទាស់។ ករណីទាំងអស់នេះ កើតនៅតាមតំបន់មួយចំនួនក្នុងបណ្តាខេត្តដូចជា ខេត្តសៀមរាប បាត់ដំបង កំពង់ធំ កំពង់ចាម បន្ទាយមានជ័យ និងក្រុងភ្នំពេញ ជាដើម។

គណបក្សសមរង្ស៊ី និងគណបក្សនរោត្តមរណឫទ្ធិ បានអះអាងថា មានករណីគំរាមកំហែងទៅលើសកម្មជនរបស់ខ្លួននៅតំបន់មួយចំនួន។ ជាក់ស្តែងនៅថ្ងៃទី ១២ មេសា ២០០៧ សកម្មជនគណបក្សសមរង្ស៊ីមួយរូបនៅក្នុងឃុំជលា ស្រុកបាធាយ ខេត្តកំពង់ចាម ត្រូវបានអធិការស្រុក កោះហៅទៅសាកសួរអំពីរឿងជម្លោះចាស់មួយដែលត្រូវបានសម្រុះសម្រួលរួចរាល់ហើយ តាំងពីថ្ងៃទី២ មេសា ២០០៧មកម្ល៉េះ។ កាលពីរាត្រីថ្ងៃទី១៣ មេសា ២០០៧ សកម្មជន គណបក្សនរោត្តមរណឫទ្ធិ នៅក្នុងឃុំឈូក ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម បានអះអាងថា ខ្លួនត្រូវបានក្មួយប្រុសរបស់ខ្លួន ដែលជាអ្នកគាំទ្រគណបក្សប្រជាជនកម្ពុជា ប៉ុនប៉ងបាញ់ខ្លួនដោយស្នាព្រួញ ប៉ុន្តែគាត់បានគេចផុតពីការស្លាប់។

ក្រៅពីនេះ ការសង្កេតឃើញមាន ឧប្បត្តិហេតុឆេះផ្ទះមួយខ្នង របស់បេក្ខជនរបស់គណបក្សសមរង្ស៊ី ជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ នៅឃុំចក្រី ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង កាលពីថ្ងៃទី ១០ មេសា ២០០៧ ដោយរកមូលហេតុមិនឃើញ។

លើសពីនេះទៅទៀត ក៏មានករណីលបលួចធ្វើឃាតទៅលើសកម្មជនគណបក្សសមរង្ស៊ីមួយរូប នៅឃុំមានឫទ្ធិ ស្រុកសណ្តាន់ ខេត្តកំពង់ធំ កាលពី ថ្ងៃទី ៦ មេសា ២០០៧។ ករណីនេះត្រូវបានគណបក្សសមរង្ស៊ីអះអាងថា ជាឃាតកម្មពាក់ព័ន្ធនឹងរឿងនយោបាយ តែអាជ្ញាធរនៅមានការសង្ស័យថា ជាអំពើហិង្សាក្នុងគ្រួសារ។

មានការចោទប្រកាន់ពីសកម្មជនគណបក្សសមរង្ស៊ី ទៅលើអាជ្ញាធរមូលដ្ឋាន ជាពិសេសថ្នាក់ភូមិ និងក្រុមមួយចំនួនថា អាជ្ញាធរមូលដ្ឋាននោះបាន ប្រើពាក្យខឹងដងដាក់សកម្មជនទាំងនោះ និងបានដើរសួរអ្នកបោះឆ្នោត ថាតើបានបោះឆ្នោតឱ្យគណបក្សនយោបាយណា? មានការឱ្យថវិកា ទៅអ្នកមិនបានទៅបោះឆ្នោត (គឺសំដៅចំពោះអ្នកដែលអាចមិនបោះឆ្នោតគាំទ្រគណបក្សកាន់អំណាច)។ ជាក់ស្តែងករណី នេះ កើតឡើងនៅក្នុងឃុំគោកដូង ស្រុកអង្គរជុំ ខេត្តសៀមរាប កាលពីថ្ងៃទី ០៨ មេសា ២០០៧ ជាដើម។

មានការចេញដីកាកោះហៅ បេក្ខជនជាប់ឆ្នោតជាជំទប់ទី ២ នៅឃុំតាគ្រាម ស្រុកបាណន់ ខេត្តបាត់ដំបង កាលពីថ្ងៃទី៥ មេសា ២០០៧ ការចោទប្រកាន់ពីសំណាក់តុលាការទៅលើបេក្ខជនទើបជាប់ឆ្នោតជាមេឃុំនៃឃុំសូភី ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី ៦ មេសា ២០០៧ និងការចេញដីកាកោះហៅចៅសង្កាត់បឹងសាឡាង ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី ១២ មេសា ២០០៧ ឱ្យទៅតុលាការបំភ្លឺបញ្ហាមួយចំនួនដូចជា ករណីបំផ្លាញទ្រព្យសម្បត្តិឯកជន ការប្រព្រឹត្តិល្មើសច្បាប់ព្រៃឈើ ឬការបង្ករបួសស្នាម (សូមបញ្ជាក់ថា សង្កាត់បឹងសាឡាង នេះ គឺគណបក្សសមរង្ស៊ីទទួលជ័យជំនះ ជាចៅសង្កាត់ជាលើកទីពីរ) ។

<u>ការវិភាគផ្ទៀងផ្ទាត់លទ្ធផលបោះឆ្នោត</u>

ខុមហ្វ្រែល និងនិកហ្វិច បាន និងកំពុងបូកសរុបលទ្ធផលពេញលេញគ្រប់ការិយាល័យរាប់សន្លឹកឆ្នោត ហើយបានផ្ទៀងផ្ទាត់ជាមួយលទ្ធផលផ្លូវការបឋមរបស់ គជប ដោយរកឃើញថា លទ្ធផលសន្លឹកឆ្នោតមាន**គំរិតលម្អៀងប្រហែល ១%** ក្នុងចំណោមឃុំ/សង្កាត់ចំនួន ៤២៧ ។ លម្អៀងនេះមិនបានធ្វើឱ្យប៉ះពាល់ដល់ការបែងចែកចំនួនអាសនៈក្រុមប្រឹក្សាឃុំ/សង្កាត់នោះទេ ។

<u>អនុសាសន៍</u>

**ខុមហ្វ្រែល និកហ្វិច និងក្រុមប្រឹក្សាយុវជនកម្ពុជា** សូមផ្តល់ជូននូវអនុសាសន៍មួយចំនួនដល់រាជរដ្ឋាភិបាលកម្ពុជា និងគណៈកម្មាធិការជាតិរៀបចំ ការបោះឆ្នោតដូចតទៅ :

- *គ.ជ.ប និងរាជរដ្ឋាភិបាល គួរតែស៊ើបអង្កេតករណីទាំងឡាយដែលទាក់ទងទៅនឹងបរិយាកាសមុនបោះឆ្នោត ដូចជាការលាក់ទុកនូវអត្តសញ្ញាប័ណ្ណសញ្ជាតិខ្មែរ និងករណីគំរាមកំហែង បំភិតបំភ័យជាដើម ។*
- *ត្រូវបង្កើតការដេដែកគ្នា ពិសេសពីគ្រប់អ្នកពាក់ព័ន្ធ ក្នុងការពង្រឹងគុណភាពបញ្ជីឈ្មោះអ្នកបោះឆ្នោត និងដំណោះស្រាយដើម្បីផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោត អំពីទីតាំងការិយាល័យឱ្យបានគ្រប់គ្នា ។ ពិសេសធ្វើការកែតម្រូវទិន្នន័យ/ព័ត៌មានអ្នកបោះឆ្នោតឱ្យបានត្រឹមត្រូវតាមសំណើអ្នកបោះឆ្នោត និងការពិនិត្យមើលឡើងវិញចំពោះការលប់ឈ្មោះអ្នកបោះឆ្នោតមិនប្រក្រតីជាច្រើន ។*
- *រាជរដ្ឋាភិបាល ដែលមានក្រសួងមហាផ្ទៃជាសេនាធិការ និងអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ត្រូវខិតខំផ្តល់អត្តសញ្ញាណប័ណ្ណ និងឯកសារបញ្ជាក់អត្តសញ្ញាណផ្សេងៗទៀត ដែលអាចប្រើនៅថ្ងៃបោះឆ្នោត ដល់ប្រជាពលរដ្ឋឱ្យបាន ១០០% ដើម្បីជៀសវាងនូវការចោទប្រកាន់នានាពីគណបក្សនយោបាយ និងភាគីនានាពាក់ព័ន្ធនឹងការបោះឆ្នោត ។*
- *ពង្រឹងសមត្ថភាពមន្ត្រីរៀបចំការបោះឆ្នោតតាមរយៈការបណ្តុះបណ្តាលបន្ថែមពីនីតិវិធីពាក់ព័ន្ធនានា តាមរយៈការកែលម្អវិធីសាស្ត្របង្រៀនដ៏មានប្រសិទ្ធភាពមួយ ។ ជាពិសេស មន្ត្រីដែល គជប បន្ថែមមួយរូបនៅខាងក្រៅការិយាល័យបោះឆ្នោត ត្រូវគោរពតួនាទី ភារកិច្ច ឱ្យបានត្រឹមត្រូវ ។*

- *ជំរុញការកែទំរង់ គ.ជ.ប និងគណៈកម្មាការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ដោយការពង្រឹង ឯករាជ្យ-ភាព និងអព្យាក្រឹតភាពរបស់ខ្លួនឱ្យបានខ្ជាប់ខ្ជួន ។*
- *បង្កើតស្ថាប័នស្របច្បាប់ឯករាជពី គជប ដើម្បីពង្រឹងការទទួលពាក្យបណ្តឹង ដោះស្រាយបណ្តឹង និងការគោរពច្បាប់ និងក្រមសីលធម៌ ។*

☏ ***ព័ត៌មានបន្ថែម សូមទាក់ទង***

| | | | |
|---|---|---|---|
| លោក **គល់ បញ្ញា** | នាយកប្រតិបត្តិ ខុមហ្វ្រែល | ទូរស័ព្ទ | ០១២ ៩៤២ ០១៧ |
| លោក **ពុន្ធរ៉ា ហេង** | នាយកប្រតិបត្តិ និកហ្វិច | ទូរស័ព្ទ | ០១២ ៩៥៩ ៦៦៦ |
| លោក **ម៉ាក សារ៉ាត** | អ្នកសំរបសំរួលក្រុមប្រឹក្សាយុវជនកម្ពុជា | ទូរស័ព្ទ | ០១២ ៩៩ ២៤ ០១ |